# មជ្ឈមណ្ឌលឯកសារកម្ពុជា

**BMI0125**

## សម្ភាសន៍ជាមួយឈ្មោះ យ៉ាន់ បេន ភេទប្រុស អាយុ៦៤ឆ្នាំ

## មុខងារជំនាន់ខ្មែរក្រហម«យោធា»

## រស់នៅភូមិថ្មដែកកេះ ឃុំបន្ទាយឆ្មារ ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ

## ថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១០

## សម្ភាសន៍ដោយៈ សុខ វណ្ណៈ

## ០០:៤៥:២០

## ២៣ទំព័រ

វណ្ណៈ: ចឹងមុនហ្នឹងខ្ញុំសម្ភាសន៍ពូចង់ចង់ប្រាប់ពូថាខ្ញុំមកពីខាងណាចឹង?

បេនៈ បាទ ។

វណ្ណៈ: ខ្ញុំឈ្មោះ សុខ វណ្ណៈមកពីមជ្ឈមណ្ឌលឯកសារកម្ពុជាដែលមានទីតាំងនៅទីក្រុងភ្នំពេញ ហើយខ្ញុំមកក៏ចង់ដឹងរឿងរ៉ាវប្រវត្តិមួយចំនួនរបស់បងប្អូនម្នាក់ៗដែលធ្លាប់ឆ្លងកាត់កន្លែងមកប៉ុន្មានជំនាន់ហ្នឹង ថាបានជួបហេតុការអីខ្លះហើយខ្ញុំចង់បានពត៌មានទាំងអស់ហ្នឹងទុកឲ្យក្មេងជំនាន់ក្រោយបានដឹងបានឮទុកជាប្រវត្តិសាស្ត្រណាពូ?

បេនៈ បាទ ។

វណ្ណៈ: ចឹងពូឈ្មោះអីដែរ?

បេនៈ ខ្ញុំឈ្មោះ យ៉ាន់ បេន ។

វណ្ណៈ: ពូអាយុប៉ុន្មានហើយ?

បេនៈ អាយុ៦៤ ។

វណ្ណៈ: ចឹងប្រពន្ធពូឈ្មោះអីដែរ?

បេនៈ ឈ្មោះ ផាត់ ផាន ។

វណ្ណៈ: គាត់អាយុប៉ុន្មានហើយ?

បេនៈ អាយុ៤២អ៊ះ៦២ ។

វណ្ណៈ: ពូមានកូនប៉ុន្មាននាក់?

បេនៈ ខ្ញុំកូន៧នាក់ ។

វណ្ណៈ: ស្រីប៉ុន្មាន?

បេនៈ ស្រី៥ ប្រុសពីរ ។

វណ្ណៈ	ចឹងឪពុកពូឈ្មោះអីដែរ?

បេនៈ	ឈ្មោះ អៀង យ៉ាន់។

វណ្ណៈ	ម្ដាយ?

បេនៈ	ម្ដាយឈ្មោះ អ៊ឹម មុំ។

វណ្ណៈ	ចឹងគាត់ទាំងពីរសព្វថ្ងៃនៅរស់ឬមួយស្លាប់ហើយ?

បេនៈ	ស្លាប់ហើយ។

វណ្ណៈ	ស្លាប់ក្រោយ៧៩ឬស្លាប់នៅពេលណា?

បេនៈ	ស្លាប់នៅឆ្នាំ៨១។

វណ្ណៈ	ចឹងស្លាប់ក្រោយ៧៩?

បេនៈ	បាទ។

វណ្ណៈ	គាត់ស្លាប់ចាស់ជរា?

បេនៈ	ស្លាប់ដោយលើសឈាម។

វណ្ណៈ	ចឹងបងប្អូនបង្កើតពូមានប៉ុន្មាននាក់?

បេនៈ	បងប្អូនមានបីនាក់តែស្លាប់មួយហើយ។

វណ្ណៈ	ចឹងស្លាប់មួយនៅសល់ពីរ?

បេនៈ	បាទ។

វណ្ណៈ	ចឹងពូមានស្រុកកំណើតនៅខាងណាវិញ?

បេនៈ	ខ្ញុំមានស្រុកកំណើតនៅត្រពាំងដីវ៍។

វណ្ណៈ	ត្រពាំងដីវ៍?

បេនៈ	បាទ!ឃុំសំឡាញ។

វណ្ណៈ	ឃុំសំឡាញ់?

បេនៈ	សំឡាញ។

វណ្ណៈ	ស្រុក?

បេនៈ	ស្រុកត្រាំកក់ ខេត្តកំពត។

វណ្ណៈ	អាក!ស្រុកត្រាំកក់នៅតាកែវតើ?

បេនៈ	ទេ ខេត្តកំពត។

វណ្ណៈ	ចឹងឥឡូវនៅភូមិអី?

បេនៈ ភូមិថ្មដែកកេះ ឃុំបន្ទាយឆ្មា ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ ។

វណ្ណៈ ចឹងកាលពីនៅតូចពូបានបួសរៀនដល់ថ្នាក់ណាដែរពូ?

បេនៈ កាលពីតូចរៀនបានថ្នាក់"កាទិដ្ឋាន" ស្មើថ្នាក់ទី៣ឥឡូវហ្នឹង ។

វណ្ណៈ ចឹងប្រហែលជាថ្នាក់ទី៩ចាស់?

បេនៈ បាទ ។

វណ្ណៈ ចឹងមានបានបួសរៀនទេ?

បេនៈ អត់មានបានបួសទេ ។

វណ្ណៈ ចឹងរៀននៅសាលាណា?

បេនៈ រៀននៅវត្តសំឡាញ់ហ្នឹងតែម្តង ។

វណ្ណៈ ចឹងឈប់រៀននៅឆ្នាំណាពូ?

បេនៈ គិតទៅប្រហែលជាឆ្នាំ៥៥-៥៦ហ្នឹង ។

វណ្ណៈ ចឹងឈប់មុនរដ្ឋប្រហារទៀត?

បេនៈ បាទ! ព្រោះខ្ញុំអាយុ១៣ឆ្នាំឈប់រៀន ។

វណ្ណៈ ចឹងនៅពេលឈប់រៀនពូធ្វើអីវិញ?

បេនៈ ខ្ញុំមកតាមឪពុកមកស្រុកគេហ្នឹងឈប់រៀនរៀនធ្វើស្រែធ្វើចំការជាមួយឪពុកចឹងទៅ ។

វណ្ណៈ ចឹងធ្វើស្រែចំការ?

បេនៈ បាទ ។

វណ្ណៈ ចឹងនៅពេលកើតមានរដ្ឋប្រហារនៅឆ្នាំ៧០ពូធ្វើអីទៀត?

បេនៈ ខ្ញុំអត់មានធ្វើអីទេ ធ្វើប្រជាជន ។

វណ្ណៈ ចឹងនៅពេលខ្មែរក្រហមចូលកាន់កាប់នៅថ្ងៃទី១៧មេសាឆ្នាំ១៩៧៥?

បេនៈ កាលហ្នឹងចូលទៅព្រៃ ។

វណ្ណៈ ចូលទៅព្រៃ?

បេនៈ បាទ ។

វណ្ណៈ វៃជាមួយទាហានលន់ នល់?

បេនៈ បាទ ។

វណ្ណៈ ពូចូលនៅឆ្នាំណាកាលហ្នឹង៧២ឬ៧៣?

បេនៈ កាលហ្នឹងចូលចិត្ត៧២ ។

វណ្ណៈ ចឹងកាលពូចូលហ្នឹង ចូលដោយស្ម័គ្រចិត្តឬពូចូលដោយយល់ឃើញថាម៉េចឬក៏តាមការអំពាវនាវរបស់សម្ដេចសីហនុឬយ៉ាងម៉េច?

បេនៈ កាលហ្នឹងរត់ទៅព្រៃ ដល់រត់ទៅព្រៃហ្នឹងក៏រត់ទៅដោយទាំងអស់តែគ្នាហ្នឹង កាលហ្នឹងគេចែកគ្នាមានដីរំដោះមានដីនេះចឹងទៅណាស់ ដីអ្នកស្រុកចឹងទៅណាស់ ។

វណ្ណៈ បាទ ។

បេនៈ កាលហ្នឹងខ្មែរក្រហមគៀទៅព្រៃ ។

វណ្ណៈ ចឹងដល់ពេលរត់ចូលព្រៃបានចូលដំរើបដិវត្តតែម្ដង?

បេនៈ បាទ ។

វណ្ណៈ កាលពូចូលហ្នឹងមានគ្នាប៉ុន្មាននាក់មានគ្នាច្រើនទេ?

បេនៈ មានច្រើនរាប់ពាន់រាប់ម៉ឺននាក់ ក្នុងមួយស្រុកទៅពាក់កណ្ដាលមកពាក់កណ្ដាល ។

វណ្ណៈ ចឹងកាលចូលដំបូងនៅខេត្តកំពតដដែលទេ?

បេនៈ អត់ទេ ខ្ញុំមកនៅស្រុកមោងនេះ ដល់ខ្ញុំមកនៅស្រុកមោងនេះបានគេកើតរដ្ឋប្រហារនេះ ។

វណ្ណៈ ចឹងពូចូលព្រៃហើយពូចូលមកដល់ស្រុកមោងពោធិសាត់ហ្នឹង?

បេនៈ ទេ ដល់ពេលនេះឪពុកនាំមកនៅស្រុកមោងនេះ តាំងពីឆ្នាំ៥៨-៥៩នេះណាស់ ។

វណ្ណៈ បាទ ។

បេនៈ ដល់នេះកើតរដ្ឋប្រហាហ្នឹង បានរត់ទៅព្រៃហ្នឹងគេទៅ ។

វណ្ណៈ ចឹងកាលឆ្នាំ៥៨-៥៩ហ្នឹងពូអត់មានបានរស់នៅខេត្តកំពតទេចឹង?

បេនៈ បាទ!អត់ទេ ។

វណ្ណៈ ចឹងមកទាំងគ្រួសារ?

បេនៈ បាទ ។

វណ្ណៈ ចឹងឆ្នាំ៥៨-៥៩មកស្រុកមោងខេត្តពោធិសាត់ មោងបាត់ដំបង?

បេនៈ បាត់ដំបង ។

វណ្ណៈ យ៉ាងម៉េចបានជាពូរត់មកខាងហ្នឹង?

បេនៈ ឪពុកម្ដាយមកនៅខាងហ្នឹង ខ្ញុំចេះក្នុងតំបន់ខ្ញុំនៅចំការលើឆ្ងាយពីថ្នល់ជាតិប្រហែលជា១៥គីឡូ ដូច្នេះដូចថាទាហានបោះទីតាំងមិនដល់ ។

វណ្ណៈ បាទ ។

បេនៈ ដូច្នេះគេគៀយកឡើងទៅលើទៅ ។

វណ្ណៈ	ចឹងតាំងពីជំនាន់៥០ជាងមកម្លេះហ្នឹង?

បេនៈ	បាទ!កាល៥០ជាងហ្នឹងខ្ញុំរស់នៅក្នុងចំការហ្នឹងភូមិព្រៃខ្លូតហ្នឹងណាស់ ។

វណ្ណៈ	បាទ ។

បេនៈ	ដល់ចឹងទៅនៅតំបន់ហ្នឹងអត់មានទាហានអីកាន់កាប់ បានគេរំដោះយកទៅព្រៃ ។

វណ្ណៈ	ចឹងឆ្នាំ១៩៧២ហ្នឹង?

បេនៈ	នៅព្រៃនោះ ។

វណ្ណៈ	ចឹងចូលបដិវត្តនៅខាងមោងហើយ?

បេនៈ	បាទ ។

វណ្ណៈ	ខាងមោងកាលហ្នឹងចូលហើយគេឲ្យហាត់រៀនអីយ៉ាងម៉េចដែរ?

បេនៈ	គេឲ្យធ្វើឈ្លបអីគ្រាន់តែយាមតាមភូមិ ។

វណ្ណៈ	ចឹងមុនដំបូងជាឈ្លប?

បេនៈ	បាទ ។

វណ្ណៈ	ចឹងដល់ពេលឆ្នាំ៧៣-៧៤ហ្នឹងគេឲ្យពូធ្វើអីវិញ?

បេនៈ	គេឲ្យធ្វើទាហាន ។

វណ្ណៈ	ហ្នឹងជាយោធា?

បេនៈ	បាទ!ដីគេកាន់កាប់ហើយយើងធ្វើតាមគេ ។

វណ្ណៈ	យោធាកាលហ្នឹងពូនៅកងពលណា ពីណាដឹកនាំខាងបាត់ដំបងហ្នឹងមេធំៗពីណាគេ?

បេនៈ	កាលហ្នឹងចូលកងភាគហ្នឹងតា ខ្វយ ។

វណ្ណៈ	តា ខ្វយ?

បេនៈ	តា ខ្វយហ្នឹងប្រធានកងពល ។

វណ្ណៈ	ចឹងតា ខ្វយហ្នឹងកងពលលេខប៉ុន្មាន?

បេនៈ	កាលហ្នឹងមិនមានទេ គេដាក់ថាភូមិភាគពាយ័ព្យហ្នឹង ។

វណ្ណៈ	ចឹងភូមិភាគពាយ័ព្យ?

បេនៈ	បាទ!តែវាមានវរៈសេនាតូចវរៈសេនាធំអីដែលណាស់ ។

វណ្ណៈ	ចឹងប្រធានភូមិពាយ័ព្យហ្នឹង រស់ ញឹមហ្នឹងពូមានដឹងទេ?

បេនៈ	ស្គាល់ដែលគ្រាន់ថាវាមិនដែលឃើញមុខពុ្រតែគេថាគេប្រធានភូមិភាគណាស់ ។

វណ្ណៈ	ចឹងតា ខ្វយប្រធានកងពល?

បេនៈ បាទ ។

វណ្ណៈ ចឹងបន្ទាប់ពីតា ខួយហ្នឹងមានពីណាទៀត?

បេនៈ បន្ទាប់ពីតា ខួយហ្នឹងមាន... តា ខួយហ្នឹងខ្ញុំស្គាល់តែកងពលហ្នឹងស្គាល់តែតា ខួយបន្ទាប់មកខ្ញុំមិនបានដឹងទេ ។

វណ្ណៈ បាទ ។

បេនៈ ចឹងមួយវរៈសេនាតូចអីវ៉ាន់ ដល់នេះគេរៀបជាកងភាគណាស់ ។

វណ្ណៈ គេរៀបយ៉ាងម៉េចខ្លះពូ?

បេនៈ កាលហ្នឹងគេរៀបចេញទៅជាកងពល វរៈ១៩ វរៈ១៧ ។

វណ្ណៈ វរៈសេនាតូច?

បេនៈ បាទ ។

វណ្ណៈ ចឹងនៅពេលដែលពូចូលចលនាហើយនៅឆ្នាំ៧៥ដែលខ្មែរក្រហមវ៉ៃចូលទីក្រុងភ្នំពេញ ពូមានបានវ៉ៃចូលដែរ?

បេនៈ ខ្ញុំមិនបានវ៉ៃចូលទេ ។

វណ្ណៈ ចឹងកាលហ្នឹងពូវ៉ៃចូលត្រឹមបាត់ដំបង?

បេនៈ ចូលត្រឹមមោង ។

វណ្ណៈ ចឹងកាលហ្នឹងមានជម្លៀសប្រជាជនចេញទេ?

បេនៈ ដឹងដែរ ។

វណ្ណៈ កាលហ្នឹងជម្លៀសប្រជាជនចេញអស់ឬយ៉ាងម៉េច?

បេនៈ អស់ ។

វណ្ណៈ ពីមោងហ្នឹង?

បេនៈ បាទ ។

វណ្ណៈ ចឹងកាលហ្នឹងពូមានគ្រួសារហើយនៅ?

បេនៈ មានហើយមានកូនពីរហើយ ។

វណ្ណៈ ចឹងដូចពូរៀបការហើយចឹងម៉េចបានជាទៅចូលចលនាចោលកូនទៀត?

បេនៈ កាលហ្នឹងមកពីគេជម្លៀសទៅព្រៃទៅ គេរឹបណែនរបស់គេទៅយើងបកមកក្រោយក៏មិនរួច ។

វណ្ណៈ ចឹងយើងត្រូវតែធ្វើទៅ?

បេនៈ ត្រូវតែធ្វើ ។

វណ្ណៈ ចឹងពូធ្វើតាំងពីមានប្រពន្ធហើយ?

បេនៈ បាទ! ចុះយើងចូលក្រញាំដៃរបស់គេហើយត្រូវតែធ្វើ ។

វណ្ណៈ ចឹងធ្វើរហូតដល់ឆ្នាំ៧៥-៧៦-៧៧ពូនៅណាវិញ?

បេនៈ ៧៧ហ្នឹងខ្ញុំមកនៅសហករណ៍វិញ ។

វណ្ណៈ ចឹង៧៧នៅសហករណ៍?

បេនៈ បាទ ។

វណ្ណៈ លែងជាយោធាហើយ?

បេនៈ បាទ ។

វណ្ណៈ នៅសហករណ៍ធ្វើអីវិញពូ?

បេនៈ ធ្វើកងចល័តអីគេវិញទៅ លើកទំនប់ជីកប្រឡាយហ្នឹងគេទៅ ។

វណ្ណៈ ព្រោះយើងមានប្រពន្ធកូនហើយ?

បេនៈ បាទ ។

វណ្ណៈ ចឹងប្រពន្ធកូនពូនៅមោងអីដែរ?

បេនៈ បាទ!នៅមោង ។

វណ្ណៈ ចឹង៧៧ហ្នឹងនៅសហករណ៍ហ្នឹងពូនៅតំបន់ណា?

បេនៈ នៅតំបន់២ ។

វណ្ណៈ ចឹងនៅតំបន់២មានគ្រោះថ្នាក់ច្រើនទេពូកាលហ្នឹង?

បេនៈ គ្រោះថ្នាក់ច្រើនណាស់ នៅតំបន់២នេះវេទនាជាងគេបំផុតហើយ ។

វណ្ណៈ ចឹងនៅតំបន់២ប្រធានតំបន់ពីណាគេ?

បេនៈ ប្រធានតំបន់កាលហ្នឹង តា វ៉ែន ។

វណ្ណៈ ចឹងក្រោយមកគេមានចាប់ខ្លួនតា វ៉ែនទេ?

បេនៈ ចាប់បាត់ ។

វណ្ណៈ ចឹងតា វ៉ែនហ្នឹងខាងពាយ័ព្យ?

បេនៈ បាទ ។

វណ្ណៈ ចឹងនៅឆ្នាំណាដែលគេចាប់តា វ៉ែន?

បេនៈ តា វ៉ែនប្រហែលជាគេចាប់នៅឆ្នាំ៧៦ព្រោះវាបាត់ឈ្មោះ ។

វណ្ណៈ	ចឹងនៅពេលចាប់គា វ៉ែនហើយមានពីណាមកគ្រប់គ្រងបន្ត?

បេនៈ	ខាងនិរតី ។

វណ្ណៈ	ពូមានស្គាល់ទេ?

បេនៈ	កាលហ្នឹងស្គាល់ត្រឹមចៅហ្វាយស្រុកគេ ។

វណ្ណៈ	ចៅហ្វាយស្រុកពីណាគេ?

បេនៈ	ចៅហ្វាយស្រុកចង់ភ្លេចឈ្មោះ..... ។

វណ្ណៈ	មិនអីទេពូ ពូមិនចាំក៏អត់អីដែរ ចឹងពូនៅកសិករកងចល័តហ្នឹងមានបានមកលេងផ្ទះ មកជួបប្រពន្ធកូនទេ?

បេនៈ	អត់ទេ នៅបែកគ្នាជួនកាលមួយខែបានមកម្តង ។

វណ្ណៈ	ចឹងរឿងហូបចុកពិបាកដែរ?

បេនៈ	វេទនាណាស់ការហូបចុក ។

វណ្ណៈ	ចឹងគេប្រើពូពីម៉ោងប៉ុន្មានដល់ម៉ោងប៉ុន្មានដល់ម៉ោងប៉ុន្មានកាលជំនាន់ហ្នឹង?

បេនៈ	ម៉ោង៧ ម៉ោង៦ទល់គ្នាដល់ម៉ោង១១បានហូបបាយ ។

វណ្ណៈ	កាលហ្នឹងបានបាយឬបានបបរ?

បេនៈ	បបរ ។

វណ្ណៈ	ចឹងកាលហ្នឹងពូហេងដែលគេអត់មានជ្រើសឈ្មោះយកទៅសម្លាប់អី គេផុតដែរ?

បេនៈ	គេចផុតដែរ យើងធ្វើពលកម្មជិតដល់បស់គេ ។

វណ្ណៈ	ចឹងគេទុក?

បេនៈ	បាទ!អ្នកដែលធ្វើពលកម្មមិនជិតដល់ហ្នឹងពិបាកដែលហ្នឹង ។

វណ្ណៈ	ចឹងកាលហ្នឹងពូមានបានឃើញអ្នក១៧មេសារងគ្រោះគេយកទៅសម្លាប់ច្រើនទេ?

បេនៈ	ឃើញតែស្លាប់ពេញតែវាលហ្នឹង ។

វណ្ណៈ	ចឹងប្រជាជនចាស់នៅហ្នឹងមានស្លាប់តិចតួចឬច្រើន?

បេនៈ	ស្លាប់ដូចគ្នា ។

វណ្ណៈ	ចឹងដែលថាពិបាកហូបចុកមែនហ្នឹងពូគិតមើលប្រហែលជាឆ្នាំណាដែលមនុស្សស្លាប់ច្រើនហ្នឹង?

បេនៈ	ពិបាកជាងគេឆ្នាំ៧៦-៧៧ហ្នឹងហើយ ។

វណ្ណៈ	ចឹងកាលពួកនិរតីចូលមកហ្នឹងពិបាកតែម្តង?

បេនៈ ពិបាកមែនទែនតែម្តងកាលហ្នឹង កាលពាយ័ព្យនៅមិនសូវអីប៉ុន្មានទេ ។

វណ្ណៈ ចឹងប្រជាជនស្លាប់ដោយសារអត់អាហារនិងយកទៅសម្លាប់ចោល?

បេនៈ បាទ!សម្លាប់ដោយសារអត់អាហារហ្នឹងវាច្រើនជាងយកទៅសម្លាប់ចោលវាស្គមស្គាំងរីង រៃទៅចេះតែស្លាប់បន្តគ្នាណាស់ ។

វណ្ណៈ កាលហ្នឹងប្រធានសហករណ៍ប្រធានគ្រប់គ្រងពូស្គាល់ទេកាលហ្នឹង?

បេនៈ ស្គាល់តើខាងនិរតីមកស្គាល់តើ ។

វណ្ណៈ ចឹងប្រធានសហករណ៍ឈ្មោះអី?

បេនៈ ប្រធានសហករណ៍ស្រី ឈ្មោះ រ៉ា ។

វណ្ណៈ ហើយមានពីណាទៀត?

បេនៈ មានឈ្មោះ រ៉ា ឈ្មោះ យ៉េត ឈ្មោះ មៀច កាលហ្នឹងមានបីដំណាក់កាលនោះ កាល ហ្នឹងមាននិរតីហើយមានខាងមស្ទឹមមកទៀត មស្ទឹមហើយនេះ ។

វណ្ណៈ ចឹងនេះខាងមស្ទឹមទេ?

បេនៈ កាលហ្នឹងនៅតំបន់២ មានមកពីរសារ ។

វណ្ណៈ មើលឥឡូវពូថាឆ្នាំ៧៦ប្រហែលជាខាងមស្ទឹមទេ?

បេនៈ បាទ ។

វណ្ណៈ ចឹងឈ្មោះ រ៉ា ឈ្មោះ យ៉េតមស្ទឹមទេ?

បេនៈ បាទ!បស្ទឹម ។

វណ្ណៈ ចឹងពួកនិរតីមកចុងក្រោយគេ?

បេនៈ មកកណ្តាល ឆ្លើយម៉េចកាត់ខុសហើយ អ្នកមកពីខាងនិរតីហ្នឹងឈ្មោះ ធី ។

វណ្ណៈ ចឹងឈ្មោះរ៉ា?

បេនៈ បាទ!ឆ្នាំ៧៧បានបស្ទឹមមក ។

វណ្ណៈ ចឹងពូអាចគិតម្តងទៀត អាចថាខាងបស្ទឹមមកមុន ព្រោះថានៅកន្លែងផ្សេងៗខាងតាកែវ មកក្រោយគេហ្នឹងតែម្តង?

បេនៈ តែខាងតំបន់២ហ្នឹងបស្ទឹមមកក្រោយ ។

វណ្ណៈ បស្ទឹមមកក្រោយវិញ?

បេនៈ បាទ ។

វណ្ណៈ ចឹងវាខុសពីកន្លែងផ្សេងៗចឹង?

បេនៈ		បាទ!ខុស ។

វណ្ណៈ		នៅកន្លែងផ្សេងៗ ខាងបស្ចឹមមកមុនហើយ ខាងនិរតីចូលមកចាប់ពួកបស្ចឹមហ្នឹងយកទៅសម្លាប់តែម្តង នៅសល់តែពួកនិរតីចុងក្រោយ?

បេនៈ		តំបន់២ហ្នឹងវាមានចេះណាស់ តំបន់២ហ្នឹងនិរតីមកមុន ដល់ចឹងទៅនិរតីហ្នឹងក៏ចាប់ពាយ័ព្យ ហើយពាយ័ព្យហ្នឹងចង់ហិនចង់ហោចហ្នឹងក៏ពួកបមស្ចឹមហ្នឹងមកចាប់និរតីវិញទៀត វាពីរជាន់ ។

វណ្ណៈ		ចឹងខ្មែរក្រហមហ្នឹងសម្លាប់ខ្មែរក្រហមគគ្នា?

បេនៈ		បាទ!សម្លាប់គគ្នាចាប់ពួកហ្នឹងអស់ ចាប់ពួកនិរតីអស់វិញ សេសសល់អ្នកដែលគ្នាល្ងង់ល្ងិតទៅណាស់ ។

វណ្ណៈ		បាទ!នៅសល់អ្នកតូចតាច?

បេនៈ		បាទៗ!នៅសល់អ្នកតូចតាច ។

វណ្ណៈ		ចឹងអ្នកធំៗ ចាប់គ្នាទៅវិញទៅមក?

បេនៈ		ចាប់គ្នាទៅវិញទៅមក ។

វណ្ណៈ		ចឹងកាលហ្នឹងសកម្មភាពមានការជ្រួលច្របល់យ៉ាងម៉េចដែរ តាមពូឃើញក្នុងហេតុការណ៍ហ្នឹង?

បេនៈ		កាលចាប់គ្នាទៅវិញទៅមកចឹង ពាយ័ព្យខាងនិរតីមកចាប់ពាយ័ព្យ ថ្នាក់ត្រឹមកម្មាភិបាលហ្នឹង ប្រជាពលរដ្ឋហ្នឹងឃើញចាប់ច្រើន ដល់បស្ចឹមនេះមកបានដាច់ប្លូហើយនេះ ។

វណ្ណៈ		បាទ ។

បេនៈ		នេះជម្លៀសទាំងខ្សែហើយ ។

វណ្ណៈ		បាទ ។

បេនៈ		គេចសឹកតែមិនចង់រួចខ្ញុំដែលហ្នឹង ដល់គេឲ្យទៅធ្វើចំការរួមចឹងទៅចេះតែមានម៉ើមដំឡូងហូបបន្តុៗ ទៅណាស់ ។

វណ្ណៈ		បាទ!ចឹងពូបានទៅនៅខាងសេដ្ឋកិច្ចវិញ?

បេនៈ		បាទ!ដល់នេះគេឲ្យខ្ញុំទៅធ្វើចំការវិញ ឆ្នាំ៧៧ហ្នឹងខ្ញុំទៅនៅចំការហើយ៧៧-៧៨ហ្នឹង ។

វណ្ណៈ		ចឹងអង្គការឲ្យធ្វើចំការ?

បេនៈ		បាទ!ធ្វើចំការរួមគេ ។

វណ្ណៈ		ចំការដាំអីខ្លះ?

បេនៈ ដាំដំឡូងម៉ី អំពៅ ។

វណ្ណៈ យកឲ្យសហករណ៍?

បេនៈ បាទ! គ្រប់គ្រងសហករណ៍ផ្តល់ឲ្យសហករណ៍សមរភូមិគេណាស់ ។

វណ្ណៈ ចឹងយើងអាចលួចហូបបានខ្លះ?

បេនៈ បាទ ។

វណ្ណៈ ព្រោះយើងអ្នកដាំ?

បេនៈ យើងអ្នកដាំគេមិនសូវឃាត់ឃាំងប៉ុន្មានទេ ។

វណ្ណៈ ចឹងប្រពន្ធកូនពូបានទៅធ្វើចំការទាំងអស់គ្នា?

បេនៈ បាទ!បានទៅទាំងអស់គ្នា ។

វណ្ណៈ ខ្ញុំធ្លាប់ដឹងដែរ ជំនាន់ហ្នឹងខ្លះបានទៅចឹញ្ចឹមមាន់ទៅអាចរស់ស្រួលដែរ ចឹញ្ចឹមមាន់ហ្នឹងដូចថាអ្នកធំ មានឈ្លបអីទៅចឹងធ្វើឲ្យហូបទៅ ចឹងបានរួចខ្លួនចឹងទៅ បើប្រជាជនសុទ្ធសាធខ្លះបានរស់ទៅខ្លះបានធ្វើនេសាទត្រីអីចឹងទៅក៏បានរស់ដែរ បើអត់មានអីហូបយើងហូបត្រីអីខ្លះទៅ ។

បេនៈ ខ្ញុំបានជូរត្រង់ថាគេឲ្យទៅនៅចំការហ្នឹង វាមានព្រៃដូចជាដំណាំចាស់ដំណាំអីណាស់ ។

វណ្ណៈ បាទ ។

បេនៈ មានចេកមានអីចាស់ចឹងទៅយើងចេះតែហូបទៅ ។

វណ្ណៈ ចឹងកាលហ្នឹងពូធ្វើចំការរហូតដល់ឆ្នាំ៧៩តែម្តង?

បេនៈ បាទ!ដល់ឆ្នាំ៧៩ ។

វណ្ណៈ ចឹងនៅពេលយួនចូលមកពូរត់ទៅណាវិញ?

បេនៈ ខ្ញុំរត់មកថ្នល់ជាតិវិញ បបួលគ្នារត់មករកថ្នល់ជាតិ ។

វណ្ណៈ រត់មករកទីរួមខេត្ត?

បេនៈ បាទ!ទីរួមស្រុក ។

វណ្ណៈ ស្រុកអីគេ?

បេនៈ ស្រុកមោង ។

វណ្ណៈ ចឹងយ៉ាងម៉េចទៀតទៅពេលពូមកដល់មោងហើយពូរៀបចំត្រឡប់ទៅស្រុកកំណើតវិញឬមួយយ៉ាងម៉េច?

បេនៈ ខ្ញុំមិនបានទៅស្រុកកំណើតវិញខ្ញុំនៅហ្នឹងឯង ។

វណ្ណៈ	ចឹងនៅហ្នឹងដល់ឆ្នាំណា?

បេនៈ	នៅបានឆ្នាំ៧៩ហ្នឹង ដល់ហើយខ្ញុំរត់មកនៅអូរហ្នឹងគេ ខ្ញុំឮដំណឹងថាខាងកាកបាទបើកអង្គរ អីឲ្យហូបខ្ញុំមកជំរំហ្នឹងគេមក ។

វណ្ណៈ	បាទ!ចឹងនៅបានរយៈពេលប៉ុន្មានខែ៧៩ហ្នឹង?

បេនៈ	កាលហ្នឹងខ្ញុំនៅរហូតដល់ខែ១២ ។

វណ្ណៈ	ចឹងខែ១២ឆ្នាំ៧៩?

បេនៈ	បាទ!ខែ១២ឆ្នាំ៧៩ហ្នឹងខ្ញុំមានស្បៀងវិចដើរមកទៅ ដើរពីមោងមករហូតដល់ស្វាយស៊ីសាផុនចឹងទៅ ។

វណ្ណៈ	ចឹងរត់ទៅជាយដែនព្រំដែនណា?

បេនៈ	មកខាងជំរំចាស់ ។

វណ្ណៈ	ទាំងគ្រួសារ?

បេនៈ	បាទ!ទាំងឪពុកម្ដាយទាំងបងប្អូនមានគ្នាប្រហែលជា៥០នាក់ ដោយទាំងអ្នកជិតខាងមកជាមួយទៀត ។

វណ្ណៈ	ជំរំចាស់ហ្នឹងខាងណាទៅ?

បេនៈ	ជំរំចាស់ចំការគហ្នឹង ។

វណ្ណៈ	ចឹងជំរំចាស់ចំការគហ្នឹងនៅក្នុងស្រុកអីដែរ?

បេនៈ	ឥឡូវហ្នឹងនៅបន្ទាយមានជ័យហ្នឹងឯង ព្រោះដីហ្នឹងនៅបន្ទាយមានជ័យ ។

វណ្ណៈ	ចឹងចំការគស្រុកថ្មពួកនេះ?

បេនៈ	បាទ ។

វណ្ណៈ	ចឹងអត់មានរត់ទៅខាងសំឡូតខាងចក្រីអីទេ?

បេនៈ	អត់ទេ ដល់យួនវៃបានខ្ញុំរត់កាលឆ្នាំ៨១យួនវៃខ្ញុំរត់ ។

វណ្ណៈ	ឆ្នាំ៨១ហ្នឹងយ៉ាងម៉េចទៅ?

បេនៈ	ឆ្នាំ៨១ហ្នឹងយួនវៃខ្ញុំរត់ទៅខាងភ្នំម៉ាឡៃ ។

វណ្ណៈ	ចឹងពូបានទៅដល់ម៉ាឡៃដំបូងពូមានឃើញម៉ាឡៃយ៉ាងម៉េច ម៉ាឡៃសម្បូរព្រៃទេ?

បេនៈ	សម្បូរព្រៃណាស់ ។

វណ្ណៈ	ឮគេថាសឹកតែមានពន្លឺថ្ងៃពេលចូលទៅ?

បេនៈ	បាទ!សឹងតែគ្មានពន្លឺថ្ងៃ ទៅវេទនានៅម៉ាឡៃហ្នឹងមួយសារទៀតខ្ញុំ ។

វណ្ណៈ	វេទនាយ៉ាងម៉េច?

បេនៈ	កាលហ្នឹងគេឲ្យទៅដឹកជញ្ជូន ដឹកជញ្ជូនឲ្យខ្មែរក្រហមទៀត ។

វណ្ណៈ	ដឹងជញ្ជូនអីគេ?

បេនៈ	ដឹកជញ្ជូនគ្រាប់ ។

វណ្ណៈ	ចឹងកាលហ្នឹងយើងមានប្រពន្ធកូនហើយគេមិនឲ្យឡើងវៃផ្ទាល់ទេ គេឲ្យដឹកគ្រាប់?

បេនៈ	បាទ! យើងអត់មានចូលទាហាននិងគេទេ យើងជាប្រជាពលរដ្ឋជាកំលាំងដឹកជញ្ជូនរបស់គេ ដឹកស្បៀងឲ្យគេ ថ្ងៃណាក៏ដឹកអង្ករៗឲ្យគេទៅ ថ្ងៃណាស្ពាយគ្រាប់ទៅ ។

វណ្ណៈ	ចឹងកាលពូរត់ទៅដល់ម៉ាឡៃមានការស្តាយក្រោយទេ គិតថាមិនគួររត់មកជាយដែនសោះគួរតែនៅស្រុកមោងមានការវិលត្រឡប់ទៅស្រុកកំណើតវិញ?

បេនៈ	កាលហ្នឹងយើងមិនដឹងរឿងចាញ់នយោបាយគេ គេថាទៅហ្នឹងគេឲ្យធ្វើចំការធ្វើពនីអីទៅនឹកឃើញថាចង់ធ្វើចំការធ្វើពនីហ្នឹងគេណាស់ ដីវាល្អដល់ទៅដល់ធ្វើចឹងទៀតទៅដល់ឆ្នាំ៨៤អីហ្នឹងវៀតណាមវៃមួយសារទៀត វៃរត់ចូលទៅតា ង៉ុកបណ្តោយ ។

វណ្ណៈ	តា ង៉ុកនៅណាវិញ?

បេនៈ	នៅសាយអេក ជំរំទី៨ កាលឆ្នាំ៨៣-៨៤វៀតណាមវៃហ្នឹងយើងរត់គេដឹកយកមកជំរំសាយអេក ។

វណ្ណៈ	ចឹងពូបានទៅដល់ជំរំហើយហេតុអីបានជាពូមិនរកវិធីសាស្រ្តណាដើម្បីទៅដល់ប្រទេសទីពប្រទេសអាមេរិចអី បារាំងអី?

បេនៈ	ទៅមិនរួចទេ ។

វណ្ណៈ	ហេតុបានជាទៅមិនរួច?

បេនៈ	ទៅមិនបាន ។

វណ្ណៈ	ហេតុអីបានជាទៅមិនបាន?

បេនៈ	រត់មិនរួច ។

វណ្ណៈ	ចឹងកាលហ្នឹងពូទៅដល់ជំរំហើយហ្នឹងរឿងអីមិនទាក់ទងបាន មានការកបាទមានអីហើយហ្នឹង?

បេនៈ	កាលនៅជំរំចាស់ហ្នឹងគេប្រមូលទៅអាមេរិចដឹងដែរ តែមិនទៅ ។

វណ្ណៈ	យ៉ាងម៉េចបានជាមិនទៅ?

បេនៈ	មកពីឪពុកមិនព្រមទៅ ។

វណ្ណៈ	ចឹង?

បេនៈ	បាទ!ឪពុកគាត់ថា ចាស់ពីដើមគាត់ឆោត គាត់ថាថៃនិងយើងហ្នឹងមិននេះទេ មិនដឹងជាដឹកទៅយកចោលត្រង់ណាទេ ដល់គាត់បន្លាញណែនាំទៅក៏មិនហ៊ានទៅ ។

វណ្ណៈ	វាកើតមានរឿងចឹងមែនដែរ?

បេនៈ	បាទ ។

វណ្ណៈ	វាអាចជួបគ្រោះថ្នាក់ចឹងមែនដែលតាមដឹងណាស់?

បេនៈ	បាទ ។

វណ្ណៈ	អាចដឹកយកទៅហើយប្លន់ទ្រព្យសម្បត្តិយើងនៅពេលហ្នឹង?

បេនៈ	បាទ ។

វណ្ណៈ	តែកាលឆ្នាំ៨៣-៨៤ហ្នឹងមានគេរត់ពីភ្នំពេញទៅដែរ?

បេនៈ	បាទ ។

វណ្ណៈ	គេបានទៅដល់អាមេរិចដល់សព្វថ្ងៃហ្នឹងដែរ?

បេនៈ	បាទ ។

វណ្ណៈ	តែការពិតទៅការផ្សងព្រេងវាមានគ្រោះថ្នាក់អីចឹងដែរ វាមើលមិនឃើញទេ?

បេនៈ	កាលឆ្នាំ៨១-៨២ហ្នឹងគេរកដឹកទៅហើយឆ្នាំ៨០គត់គេប្រកាសមេក្រូហើយម៉ោង៨គេប្រកាសហៅអ្នករកទៅខាវដាងណាស់ ។

វណ្ណៈ	បាទ ។

បេនៈ	តែខ្ញុំនឹកឃើញថាខាវដាងខ្លាចវាលំបាកហូបទៀត នឹកឃើញថាចង់មកស្រុកវិញនេះ ចង់មកស្រុកមកទេសវិញនេះ ។

វណ្ណៈ	បាទ ។

បេនៈ	សន្សំលុយកាក់បានមកស្រុកវិញ ដល់សន្សំលុយកាក់បានមនុស្សចេះតែនៅច្រើននៅអុកឡុកគេ នៅសប្បាយហ្នឹងគេទៅ ។

វណ្ណៈ	បាទ ។

បេនៈ	នឹកឃើញថារបបស៊ីស្រាប់ ។

វណ្ណៈ	បាទ ។

បេនៈ	ដល់ចឹងវៀតណាមវៃជំរំទៅបានភ្ញាក់ខ្លួនមកមិនរួច ។

វណ្ណៈ	ដល់ចឹងនៅតាមគេតាមឯងទៅ?

បេនៈ	នៅតាមគេតាមឯងទៅ ចុះមនុស្សរាប់ម៉ឺបនាក់ រាប់ម៉ឺនរាប់សែន។

វណ្ណៈ	ចឹងកាលសម្តេចចុះមកដល់សាតាំងនៅភូមិដូងពូមានបានដឹងទេ?

បេនៈ	អត់ទេ នៅខាងនោះ។

វណ្ណៈ	ចឹងភាគច្រើនពូនៅជំរំ?

បេនៈ	បាទ!នៅជំរំសាយអេក។

វណ្ណៈ	ចឹងពូនៅសាយអេកដល់ឆ្នាំណាបានពូរត់មកជិតនារខាងនេះវិញ?

បេនៈ	ខ្ញុំវាដំណាក់ឆ្ងាយណាស់ គេដឹកចេញពីសាយអេកហ្នឹងដោយសារវាវេទនាពេកថៃចេះតែអុកឡុកខ្លាំងពេក គេដឹកទៅភ្នំដងរែក។

វណ្ណៈ	ដងរែកនៅខាងជិតនារណាដែល?

បេនៈ	នៅដុបគគីរ។

វណ្ណៈ	ដុបគគីរនៅខាងណាវិញ?

បេនៈ	ដុបគគីរនៅចំនេះមានបងប្អូនគេមកហ្នឹងថានៅហ្នឹងវាទូលាយស្រួលរកស៊ីជាងមកដុបគគីរនេះទៀត។

វណ្ណៈ	ចឹងឆ្នាំណាដែលពូមកដុបគគីរ?

បេនៈ	ដុបគគីរបែប៨៦។

វណ្ណៈ	រត់ពីជំរំ?

បេនៈ	បាទ!រត់ពីសាយអេកមក មកភ្នំដងរែក។

វណ្ណៈ	ដឹកតាមផ្លូវថៃ?

បេនៈ	បាទ!ដឹកតាមផ្លូវថៃ។

វណ្ណៈ	មកនៅភ្នំដងរែក?

បេនៈ	បាទ!នៅដុបគគីរហ្នឹងតែម្តងហ្នឹងមានជំរំច្រើនមានជំរំប៉ារាជងនិងជំរំខ្មែរក្រហមផង។

វណ្ណៈ	ចឹងកាលហ្នឹងដឹកឡានតាមផ្លូវថៃ?

បេនៈ	បាទ!តាមផ្លូវថៃ។

វណ្ណៈ	កាលហ្នឹងមានប្រជាជនច្រើនទេដែលមក?

បេនៈ	មកកាលហ្នឹងមានមនុស្សរាប់ម៉ឺនរាប់ពាន់។

វណ្ណៈ	ចឹងកាលហ្នឹងខ្លះមានសំណាងចេញទៅក្រៅខ្លះមិនចេញទៅ?

បេនៈ បាទ!ខ្ញុំទៅផ្សេងព្រៃងទៅក៏បានទៅរួច ទៅហើយគេចាប់មកវិញក៏មានថៃធ្វើបាបក៏មាននិយាយឲ្យត្រង់ទៅខ្ញុំមិនមានបំណងចិត្តចង់ទៅ ។

វណ្ណៈ បាទ ។

បេនៈ នឹកឃើញថាដីធ្លីនៅស្រុកវាធំធេងណាស់ ថាចូលមកវិញបានដីមកតែដល់ទៅគេមិនឲ្យ ។

វណ្ណៈ បាទ ។

បេនៈ ធ្លាយទៅផ្ទះវិញ ឆ្នាំ៨៦-៨៧ហ្នឹង ។

វណ្ណៈ ឆ្នាំ៨៦-៨៧ហ្នឹងពូមកនៅនេះ?

បេនៈ កាលឆ្នាំ៨៦-៨៧ហ្នឹងខ្ញុំហ៊ានឈ្លបចូលមកក្នុងទៅមើលស្រែទៅមើលផ្ទះ ។

វណ្ណៈ ចឹងពូហ៊ានទៅតែឯងទេ?

បេនៈ បាទ!ហ៊ានទៅតែឯង ។

វណ្ណៈ ចេញតាមស្វាយស៊ីសាផុនទៅប្រឡាំៗទៅតាមស្វាយទៅដល់ម៉ោងទៅមើល?

បេនៈ បាទ!ទៅដល់ម៉ោងទៅមើល ។

វណ្ណៈ ចឹងដល់ទៅមើលគេនៅអស់ហើយ?

បេនៈ បាទ!គេនៅអស់ហើយគេមិនឲ្យវិញទេ ។

វណ្ណៈ ចឹងបើសិនជាគេឲ្យវិញពូនាំកូនចៅទៅទេ?

បេនៈ បាទ ។

វណ្ណៈ ចឹងនាំចេញទៅបានទេព្រោះអីនៅឆ្នាំ៨៦ហ្នឹងយើងត្រូវឆ្លងកាត់វៀតណាមអីណាស់?

បេនៈ បាទ!បាន ។

វណ្ណៈ ចឹងនៅពេលដែលយើងឆ្លងទៅចឹងទាហានខាងវៀតណាមទាហានខាងសាធារណរដ្ឋប្រជាមានិតកម្ពុជាសង្ស័យទេ?

បេនៈ គេសង្ស័យដែលតែយើងចេះតែលាក់លៀមនិងគេទៅ យើងមានបងប្អូននៅហ្នឹងយើងចេះតែសង្វាត់និងគ្នាទៅ ចឹងបានទៅកើត ។

វណ្ណៈ បាទ ។

បេនៈ ខ្ញុំមានរយៈបងប្អូននៅស្វាយទៅដល់ទៅជាមួយគេទៅដូចយើងអ្នកនៅស្វាយចឹង ។

វណ្ណៈ ចឹងកាលពូមកនៅទីនេះឆ្នាំ៨៥-៨៦ពូអត់មានចូលចលនាអីទៀតទេ?

បេនៈ ទេ ខ្ញុំឈប់រហូត ។

វណ្ណៈ	ចឹងកាលដែលពូនៅហ្នឹង ពូមានជួបផលលំបាកអីខ្លះទេ នៅពេលវៀតណាមវ៉ៃចូលខ្មែរក្រហមវ៉ៃចូលអីចឹង?

បេនៈ	មានការលំបាកខ្លាំងណាស់នៅនេះ ។

វណ្ណៈ	ចឹងនិយាយទៅរងគ្រាប់?

បេនៈ	បាទ!រងគ្រាប់ ។

វណ្ណៈ	ចឹងមានប្រជាជនស្លាប់ដោយសារវ៉ៃគ្នាហ្នឹងដែរ?

បេនៈ	ប្រជាជនមិនមានស្លាប់តែនៅនេះវាហិនហោចកាលឆ្នាំ៩៥-៩៦ចឹងណាស់ កាលហ្នឹងគេហៅភូមិអភិវឌ្ឍន៍ គេដឹកពីមណ្ឌលកងវ៉ាមកវិញណាស់ ។

វណ្ណៈ	បាទ ។

បេនៈ	ដល់មកនៅនេះទៅវាមានការលំបាក គេប្លន់យប់ឡើងទាហានយើងហ្នឹងវាលំបាកហើយខ្លាចគេទាហានគេដឹកស្រវឹងទៅគេធ្វើបាប ។

វណ្ណៈ	បាទ ។

បេនៈ	ម្ល៉ោះហើយចេះតែគេចចេះតែពួនទៅ ឃើញថាមិនទៀងផងហើយបានអង្គការក្រៅរដ្ឋាភិបាលហ្នឹងមកចែកដីឲ្យនេះម្នាក់ហ្នឹងមួយគ្រួសារហ្នឹងដីស្រែបានចំនួនមួយហិចតា ចំការបានចំនួនមួយហិចតា ។

វណ្ណៈ	ចឹងកាលនៅជុបគគីរពូនៅឆ្នាំណាហើយបានចូលមកដល់ភូមិនេះតាំងពីពេលណា?

បេនៈ	កាលហ្នឹងខ្ញុំចុះទៅក្រឡាញ់វិញ ដល់ចឹងទៅមានកងទ័ពខ្មែរក្រហមហ្នឹងទៅចេះខ្ញុំមានស្គាល់គេហ្នឹងខ្ញុំនាំគ្រួសារចុះទៅនៅក្រឡាញ់ ។

វណ្ណៈ	ឆ្នាំណាដែលនៅក្រឡាញ់?

បេនៈ	ប្រហែលជាឆ្នាំ៩២-៩៣ហ្នឹង ។

វណ្ណៈ	បាទ ។

បេនៈ	ដល់ហ្នឹងចោរប្លន់យកអស់មួយម្ដង ទៅដល់ហ្នឹងរកស៊ីបានខ្លះហ្នឹងចោរប្លន់អស់ទៅ កាលហ្នឹងប៉ារ៉ាវ៉ៃខ្មែរក្រហមវិញ គេថាខ្ញុំនៅក្នុងភូមិដាច់ពីគេ ព្រោះឯងភូមិចាស់សុទ្ធតែភូមិគេណាស់ ។

វណ្ណៈ	បាទ ។

បេនៈ ទៅនៅធ្វើជំរំគ្នាឯងហ្នឹងប្រហែលជា១០ទៅ២០គ្រួសារហ្នឹង គេថាឯងហ្នឹងជាខ្មែរយៈ ខ្មែរក្រហមហ្នឹង ប៉ុរាគេរើយកគោយកក្របីអស់ម្តងទៀតទៅ ទើបសន្សំបានគោមួយនឹម និងដីស្រែ៩ហិចតាហ្នឹងគេរើយកអស់ក៏រត់មកនេះទៀតទៅនៅមិនបាន ។

វណ្ណៈ ចឹងកាលហ្នឹងមានទាហានប៉ុរានិងទាហានយួនតើទាហានខាងណាខូចជាងខាងណាមើលទៅ តាមពូគិត?

បេនៈ ខូចជាងគេទាហានប៉ុរា ។

វណ្ណៈ ចឹងច្រើនតែទាហានប៉ុរា?

បេនៈ បាទ ។

វណ្ណៈ ខ្ញុំឮគេនិយាយដែរពេលចូលមកដល់ក្នុងភូមិទៅ ដេញទាហានយួនចេញទៅ ចូលដល់ក្នុង ភូមិចាប់ជ្រូកចាប់គោយកទៅ?

បេនៈ ចាប់ជ្រូកចាប់គោយកលុយ ។

វណ្ណៈ ចឹងយកលុយប្រជាជន?

បេនៈ យកលុយខ្ញុំមានគោមួយនឹមឲ្យខ្ញុំបង់១០០០០បាតបានវាអត់យកគោ ។

វណ្ណៈ ១០០០០បាតជំនាន់នោះមិនងាយណាហ្នឹង?

បេនៈ ឲ្យវា១០០០០បាតហើយបានវាឲ្យគោមកវិញ កាលហ្នឹងតម្លៃតែ៦ទៅ៧ពាន់ទេ ។

វណ្ណៈ ចឹងប៉ុរាហ្នឹងមានប៉ុរាខាងណាខ្លះពូមានដឹងទេ?

បេនៈ មានខាង តា សឺនសាន ។

វណ្ណៈ ចឹងខាងសម្តេចក្រុមព្រះមានទេ?

បេនៈ ចម្រុះគ្នាទាំងអស់ កាលហ្នឹងវាមានពីរបីភាគីនោះ ។

វណ្ណៈ ចឹងខាងយួនចូលមកដល់ហ្នឹងមានចាប់យកគោយកក្របីពីប្រជាជនទេ?

បេនៈ ខាងវៀតណាមមិនដែលយកគោយកក្របីទេ ខែខាងប៉ុរាច្បាស់ជាយកគោក្របីតែម្តង ។

វណ្ណៈ ចឹងនៅពេលហ្នឹងយួនមកដល់ក្នុងភូមិមិនដែលមកយកគោក្របីពីប្រជាជនទេ?

បេនៈ បាទ ។

វណ្ណៈ ចឹងខាងនោះគេល្អជាង?

បេនៈ បាទ! គេមិនដែលមកយកគោក្របីទេ លុះត្រាណាយើងធ្វើអំពើខុសឆ្គងបានគេចាប់ណាស់ បើខាងនេះដឹងថាយកហើយយើងនិយាយការជាក់ស្តែងតែម្តង ។

វណ្ណៈ	បាទ!ចឹងនៅពេលដែលទាហានយួននិងទាហានសាធារណរដ្ឋប្រជាមានិតកម្ពុជាវ៉ៃចូលក្នុងភូមិចឹង ខ្មែរក្រហមនិងប៉ុលពតដកទៅចឹង តើមានមកសម្លុតប្រជាជនយកលុយយកកាក់ពីប្រជាជនទេ?

បេនៈ	អត់ មិនដែលប៉ះ តែពួករដ្ឋកម្ពុជាថយមកវិញ ពួកអស់លោកហ្នឹងមកគេថាឯងខ្មែរយៈខ្មែរអីគេចេះតែចាប់គ្នាជាការមិនពិត អាហ្នឹងធ្វើដើម្បីលុយ ។

វណ្ណៈ	ចឹងទាហានខាងនោះមិនអីវិញ?

បេនៈ	បាទ ។

វណ្ណៈ	ទាហានខ្មែរក្រហមនិងទាហានប៉ុលពតនេះ?

បេនៈ	ខ្មែរក្រហមក៏មិនដែលបង្អាប់យកលុយយកកាក់ដែរ ។

វណ្ណៈ	ចឹងខ្មែរក្រហមក៏មិនដែលដែរ?

បេនៈ	បាទ ។

វណ្ណៈ	ចឹងខូចជាងគេតែទាហានប៉ុលពតធ្វើបាបប្រជាជន?

បេនៈ	បាទ!ខ្ញុំខំធ្វើស្រែបាន៨ទៅ៩ហិចតាទៅហើយ ។

វណ្ណៈ	ចឹងពូបោះទីតាំងនឹងថ្កល់នៅនេះតែម្តងតាំងពីឆ្នាំណា ដូចថាពូលែងរត់លែងអីទៀតហើយ?

បេនៈ	លែងរត់តាំងពីឆ្នាំ៩៥ ។

វណ្ណៈ	៩៥?

បេនៈ	បាទ ។

វណ្ណៈ	ចឹង៩៥មានអ៊ុនតាក់ចូលមកពូមានបោះឆ្នោតអីដែរ?

បេនៈ	បាទ!បានបោះឆ្នោតនិងគេ ។

វណ្ណៈ	ចឹងកាលវៀតណាមដកទៅនៅឆ្នាំ៨៧ហ្នឹងនៅសល់តែខ្មែរនិងខ្មែរវ៉ៃគ្នាកាលហ្នឹងលែងសូវមានសង្គ្រាមខ្លាំងហើយមែនទេ?

បេនៈ	បាទ!លែងខ្លាំងហើយតែសម្បូរចោរ ។

វណ្ណៈ	ចឹងសម្បូរចោរវិញ?

បេនៈ	បាទ!មានចោរលួចឆក់ញឹកណាស់ និយាយទៅបន្ទាប់តែខ្មែរគ្នាឯងពិសេសទាហានប៉ុលពតដើរឆក់ដើរប្លន់គេ ចេះតែខ្លាចគេទៅណាស់ ។

វណ្ណៈ	ចឹងយប់អីក៏មិនបានដេកស្រួលដែរ?

បេនៈ ដេកមិនដែលបានពេញភ្នែកទេ យើងទើបបានស្រួលពេលត្រូវគ្នានេះហើយទេ ។

វណ្ណៈ បាទ ។

បេនៈ កាលហ្នឹងត្រូវគ្នាហើយហ្នឹងនៅតំបន់នេះខាងប៉ារាគេកាន់កាប់កាលហ្នឹងយប់ឡើងមិនចង់ហ៊ានដេក ។

វណ្ណៈ ចឹងប៉ារានិងខ្មែរក្រហមពេលជួបគ្នាយ៉ាងម៉េចដែរ?

បេនៈ ទេ អាសត្វហ្នឹងវាខោកគ្នាទៅវិញទៅមក ដួនថ្ងៃណាវាត្រូវវាត្រូវទៅខុសតាមមេតាមកើយចឹងណាស់ ។

វណ្ណៈ បាទ ។

បេនៈ បើមេណាធ្លាប់ត្រូវគ្នាត្រូវគ្នាទៅបើមេណាមិនត្រូវគ្នាវាបាញ់គ្នាទៅ ។

វណ្ណៈ ចឹងបាញ់គ្នាលេងទៅហើយយើងភ័យលាន់ទៅ?

បេនៈ បាទ!យើងភ័យទៅវាលំបាកចឹងដែលខ្មែរយើង ។

វណ្ណៈ ចឹងពូនៅនេះពូមិនមែនជាអ្នកស្រុកកំណើតនៅនេះទេ ពូជាអ្នកថ្មីដែលតែតាមពូដឹងពូមកនៅទីនេះ ចឹងពូមានដឹងថាស្រុកភូមិនេះកើតមានរាប់រយឆ្នាំមកដែរ?

បេនៈ បាទ ។

វណ្ណៈ ចឹងភូមិគេនេះមិនមែនទើបកើតទេ គឺមានតាំងពីបុរាណមក?

បេនៈ បាទ!មានតាំងពីសម័យសង្គមរាស្ត្រនិយមនោះ ពួកនៅនេះមាននេះណា ។

វណ្ណៈ ចឹងនិយាយទៅមានតាំងពីសម័យអង្គរនៅនេះមានទាំងបន្ទាយឆ្នានេះ?

បេនៈ បាទ ។

វណ្ណៈ ចឹងអាចកើតមានរាប់ពាន់ឆ្នាំមក?

បេនៈ រាប់ពាន់ឆ្នាំមក ។

វណ្ណៈ ចឹងពូមកនៅនេះមានដែលទៅលេងបន្ទាយឆ្នាដែរ?

បេនៈ បាទ!ទៅលេងទៅវត្តអីហ្នឹង ។

វណ្ណៈ ចឹងមានវត្តនៅហ្នឹងទៀត?

បេនៈ បាទ!ទៅធ្វើបុណ្យទាននៅវត្តបន្ទាយឆ្នាហ្នឹង ។

វណ្ណៈ ចឹងវត្តបុរាណមាននៅសេសសល់ដែលឬមួយអស់ហើយ?

បេនៈ មិននៅសល់ប៉ុន្មានទេ នៅតិចតួច ។

វណ្ណៈ ចឹងកាលហ្នឹងមានប្រាសាទបាក់បែកខ្លះ កាលហ្នឹងពូថាខាងប៉ុលពតឲ្យប្រជាជនជីកចឹងមែនឬ មួយយ៉ាងម៉េច?

បេនៈ គេឲ្យមនុស្សជីកគេឲ្យតម្លៃ ។

វណ្ណៈ ចឹងពូមានបានដឹងទេ?

បេនៈ ដឹងដែលតែខ្ញុំមិនដែលហ៊ានទៅជិតគេទេ របស់ចេះៗខ្ញុំមិនសូវហ៊ានសោះ ។

វណ្ណៈ ហ្នឹងហើយអ្នកយកចឹងអត់មានកំណើតអីដែលហ្នឹង យករបស់បុរាណអីហ្នឹងយកទៅលក់ឲ្យ គេចឹង?

បេនៈ បានត្រឹមទៅឆ្កាព្រៃ ។

វណ្ណៈ គេទំថែរក្សាចង់ងាប់ឯងគិតតែពីយកលក់ឲ្យគេ?

បេនៈ អ្នកភូមិអស់នេះបានត្រឹមម៉ាទៅឆ្កាព្រៃ ព្រៃវាដុះចង្អែតពេកចឹង គេកេណ្ឌទៅឆ្កាអីចឹងទៅ ណាស់ ។

វណ្ណៈ បាទ ។

បេនៈ តែរបស់គេជីកអីនោះគេមិនដែលឲ្យមនុស្សចំណូលយើងនេះទេ គេជីកតែគ្នាគេហ្នឹងណាស់ ។

វណ្ណៈ ចឹងពូមកដល់ឥឡូវពូមានដែលបានទៅលេងស្រុកកំណើតនៅខាងខេត្តកំពតទេ?

បេនៈ ខ្ញុំនៅឡើយ ខានទៅហ្នឹងគិតមើលតាំងពីឆ្នាំ៧០មក ។

វណ្ណៈ ចឹងពូមិនដែលទៅសោះ?

បេនៈ មិនដែលទៅសោះ ។

វណ្ណៈ យ៉ាងម៉េចចឹង?

បេនៈ ខ្ញុំដំណាក់កាលវាលំបាកមួយដំណាក់ៗ កាលហ្នឹងចិញ្ចឹមម្តាយចាស់មួយប្អូនជរាមួយដល់ មួយឆ្នាំហើយថាមួយឆ្នាំៗៗចឹងទៅណាស់ ។

វណ្ណៈ បាទ ។

បេនៈ ហើយម្តាយហ្នឹងទើបស្លាប់ឆ្នាំ២០០០ប៉ុន្មានទេ ស្លាប់បានបីឆ្នាំហើយ ។

វណ្ណៈ ចឹងម្តាយឪពុកស្លាប់នៅហ្នឹងដែរ?

បេនៈ ម្តាយស្លាប់នៅនេះ គាត់ជរាអាយុ៨០ជាងហើយគាត់ជរារកទៅមិនរួច ។

វណ្ណៈ ចឹងអត់មានទៅរកអីពូមីងមាអីទេ?

បេនៈ បាទ!មិនទាន់បានទៅទេ ថាឆ្នាំនេះទៅមិនដឹងជាយ៉ាងណាទេ តែបងប្អូនគេមកញឹកដែរ ។

វណ្ណៈ ចឹងមានបងប្អូនមកលេងវិញ?

បេនៈ បាទ ។

វណ្ណៈ ចឹងពូអត់មានថាទៅមើលទឹកដីកំណើតអីបន្តិច?

បេនៈ ថាចង់ទៅតែមិនទាន់បានទៅ ។

វណ្ណៈ តែដីថ្មីគេយកអស់ហើយយើងមិនទៅចឹង?

បេនៈ ទេ អត់មានចង់បានអីទៀតទេ វាអស់ហើយដី បងប្អូនមកប្រាប់គេយកអស់ហើយ ។

វណ្ណៈ ចឹងនៅទីនោះមានបងប្អូនបង្កើតដែរ?

បេនៈ អត់ទេ ខ្ញុំមកនៅទីនេះទាំងអស់គ្នា ។

វណ្ណៈ ចឹងបានជាពូមិនចង់ទៅវិញ?

បេនៈ ខ្ញុំចេះរៀងកាលទៅហ្នឹង ខាងគ្រួសារឪពុកម្ដាយខ្ញុំហ្នឹងនៅខាងម្ដាយហ្នឹងនៅមានក្មួយនៅស្រុកណាស់ ។

វណ្ណៈ បាទ ។

បេនៈ តែបងៗប្អូនគាត់អីស្លាប់អស់ហើយ ។

វណ្ណៈ បាទ ។

បេនៈ ហើយខាងឪពុកខ្ញុំគាត់ពោះមួយតែបីនាក់ ក៏ស្លាប់អស់ដែរ មកស្លាប់នៅនេះមួយទៅស្លាប់នៅជាយដែនមួយ ស្លាប់នៅភ្នំពេញនោះមួយ ។

វណ្ណៈ បាទ ។

បេនៈ កាលមុននៅជុំគ្នាទាំងអស់ ។

វណ្ណៈ បាទ ។

បេនៈ តែដល់ពេលនេះទៅតាមកូនតាមចៅ ឆ្នាំនេះថាទៅមិនដឹងជាយ៉ាងម៉េចចាំមើល ។

វណ្ណៈ តែទៅត្រូវចំណាយលុយអស់ច្រើនដែរ?

បេនៈ ចង់ទៅហ្នឹងគោលបំណងខ្ញុំចង់តែទៅលេងក៏ទៅមិនកើត ទៅនេះវាកំណត់ពុកខ្ញុំកាលគាត់រស់នៅក្នុងស្រុកមោងនេះណាស់ ។

វណ្ណៈ បាទ ។

បេនៈ បើថាគាត់ទៅចឹងគាត់ទៅធ្វើបុណ្យមួយពេលចឹងទៅ កាលហ្នឹងលុយវាថ្លៃអស់តែ២ទៅ៣ពាន់ទៅគាត់ធ្វើហើយ ។

វណ្ណៈ បាទ ។

បេនៈ ហើយខ្ញុំនេះបើសិនជាខ្ញុំទៅទាល់តែមានលុយ បើសិនជាលុយខ្មែរប្រហែលជាមួយលានជាងហើយ ធ្វើលុយបាតទាល់តែ១០០០០បានធ្វើកើត ។

វណ្ណៈ បាទ ។

បេនៈ និមន្តលោកឆាន់មួយពេលទៅ ខ្លះទៅលិបលៗទៅតែលេងចឹងខ្ញុំមិនទៅទេ ចំពោះតែទៅលេងមិនទៅទេ ទៅទាល់ទៅធ្វើបុណ្យទានជួបជុំបងប្អូនណាស់ ។

វណ្ណៈ បាទ!ចឹងខ្ញុំជាអស់អីសួរពូហើយ ខ្ញុំចង់សួរយោបល់ចុងក្រោយ ដូចថាពូធ្លាប់ឆ្លងកាត់ធ្លាប់បំរើបដិវត្តអីចឹងដែរ ហើយក្រោយមកជួបការលំបាកសព្វបែបយ៉ាង ធ្លាប់ឃើញប្រជាជនស្លាប់អីចឹង ចឹងពូគិតថាការស្លាប់របស់ប្រជាជនការអត់បាយរបស់ប្រជាជនហ្នឹង ពូគិតថាថ្នាក់ដឹកនាំនៅក្នុងសម័យហ្នឹងគេដឹងដែរ ឬមួយគេធ្វើមិនដឹងអីយ៉ាងម៉េចពូ នេះបើតាមអារម្មណ៍របស់ពូគិត?

បេនៈ ខ្ញុំថាដឹង ។

វណ្ណៈ ចឹងពីគិតថាដឹង?

បេនៈ បាទ ។

វណ្ណៈ ហេតុអីទៅ?

បេនៈ ព្រោះដឹងហ្នឹងមកពីជាន់គ្នាទៀមទាតែរឿងធំ ដូចថាភូមិភាគនេះមកថាអានេះល្អជាងអានេះ អានេះល្អជាងអានោះចឹងទៅ ចឹងប្រជាជនពលរដ្ឋដូចជាសម្រាមចឹង ។

វណ្ណៈ បាទ ។

បេនៈ បើគេថាអានោះវាក្បត់ទៅហើយ កាលពីដើមភូមិភាគពាយ័ព្យហ្នឹងមិនសូវមានមនុស្សស្លាប់ប៉ុន្មានទេ ។

វណ្ណៈ បាទ ។

បេនៈ វានៅគ្រាន់រស់ដល់ពេលនិរតីមកនេះ គេថាភូមិភាគពាយ័ព្យហ្នឹងក្បត់ ។

វណ្ណៈ បាទ ។

បេនៈ ដល់ក្បត់គេចំរាញ់មនុស្ស ។

វណ្ណៈ បាទ ។

បេនៈ ជ្រើសរើហើយណាស់ ខ្មែរកម្មាភិបាលខ្មែរអីហ្នឹង គេជ្រើសរើសគ្នាគេហ្នឹងហើយប្រជាពលរដ្ឋមានការស្លាប់ដូចគ្នាហ្នឹង ។

វណ្ណៈ បាទ!ចឹងពូគិតថា ថ្នាក់ដឹកនាំដូចតា នួន ជា តា អៀង សារី តា ប៉ុល ពត តា ខៀវ សំផន ឌុចអីវ៉ាន់ហ្នឹង ពេលគេចាប់មកកាត់ទោសចឹង ពូគិតថាជាការត្រឹមត្រូវឬមួយមិនត្រឹមត្រូវទេ?

បេនៈ ខ្ញុំគិតថាជាការត្រឹមត្រូវ ព្រោះពួកទាំងអស់នេះមានថាមិនដឹងឯណា ព្រោះអ្នកដឹកនាំ ។

វណ្ណៈ បាទ ។

បេនៈ ដឹកនាំគេធ្វើណាស់ ។

វណ្ណៈ បាទ ។

បេនៈ ចឹងការចុងបញ្ចប់គេស្លាប់ទៅហើយ ហើយយើងថាមិនដឹងយ៉ាងម៉េចកើត ។

វណ្ណៈ ចឹងមានន័យថាមេដឹកនាំខ្មែរក្រហមត្រូវតែមានការទទួលខុសត្រូវ?

បេនៈ បាទ ។

វណ្ណៈ ចឹងពូគិតថាតុលាការមានសារសំខាន់និងមានផលប្រយោជន៍ទេ?

បេនៈ មានសារសំខាន់និងមានផលប្រយោជន៍ កុំឲ្យជាប់ដានទៅថ្ងៃក្រោយទៀត ។

វណ្ណៈ បាទ ។

បេនៈ ហើយអ្នកដែលទទួលធ្វើហ្នឹងត្រូវតែទទួលទោសហ្នឹងតែម្តង ដឹកនាំគេមិនបានល្អណាស់ ។

វណ្ណៈ បាទ!ចឹងខ្ញុំអត់មានអីសួរពូទៀតខ្ញុំអរគុណពូច្រើនហើយ?

បេនៈ បាទ! បើខ្ញុំនិយាយលើសលួសខ្វះខាតត្រង់ណាសូមកុំប្រកាន់ ។

វណ្ណៈ មិនអីទេ ពូ ខ្ញុំសូមអរគុណពូ ។

បេនៈ បាទ ។

**ចប់**